# សំណួរដែលចោទសួរជាញឹកញាប់អំពីវ៉ាក់សាំងកូវីដ-19 សម្រាប់កុមារអាយុពី 6ខែដល់ 5ឆ្នាំ

## ហេតុអ្វីបានជាកុមារអាយុក្រោម 5ឆ្នាំគួរតែទទួលវ៉ាក់សាំងកូវីដ-19?

ជំងឺកូវីដ-19 អាចធ្វើឲ្យកុមារឈឺធ្ងន់ធ្ងរបាន។ កុមារនិងជំទង់រាប់មឺននាក់ដែលមានជំងឺកូវីដ-19 បានចូលសម្រាកពេទ្យ ហើយផលប៉ះពាល់រយៈពេលវែងនៃជំងឺកូវីដពិតជាកើតមានក្នុងចំណោមកុមារ។

វ៉ាក់សាំងគឺជាវិធីដ៏ល្អបំផុតក្នុងការបង្ការកូនរបស់អ្នកកុំឲ្យធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។ វាជួយការពារកុមារតូចៗដែលមិនអាចពាក់ម៉ាស ឬរក្សាគម្លាតឆ្ងាយពីគ្នាបាន។ ការចាក់វ៉ាក់សាំងដល់កុមារក៏អាចជួយការពារមនុស្សជាទីស្រឡាញ់ដែលមានហានិភ័យប្រឈមនឹងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺកូវីដ-19។

## តើមានអ្វីកើតឡើងបើកូនរបស់ខ្ញុំធ្លាប់បានកើតជំងឺកូវីដ-19 រួចហើយ?

កុមារគួរតែបន្តទទួលការចាក់វ៉ាក់សាំង បើទោះបីជាពួកគេបានកើតជំងឺកូវីដ-19 ហើយក៏ដោយ។អ្នកដែលបានចាក់វ៉ាក់សាំងគ្រប់ចំនួន ទទួលបានការការពារល្អប្រសើរជាងអ្នកដែលគ្រាន់តែបានឆ្លងជំងឺកូវីដ-19។ប្រសិនបើកូនរបស់អ្នកធ្លាប់បានកើតជំងឺកូវីដ ពួកគេអាចទទួលការចាក់វ៉ាក់សាំងបាននៅពេលណាពួកគេជាសះស្បើយពីជំងឺ ហើយរយៈពេលនៃការដាក់ឲ្យស្ថិតនៅដាច់ដោយឡែកបានបញ្ចប់។

## ប្រសិនបើខ្ញុំបានទទួលវ៉ាក់សាំងកូវីដ-19 នៅអំឡុងពេលមានផ្ទៃពោះ តើកូនរបស់ខ្ញុំនៅតែចាំបាច់ត្រូវចាក់វ៉ាក់សាំងទៀតដែរឬទេ? តើមានអ្វីកើតឡើងបើខ្ញុំបានចាក់វ៉ាក់សាំងហើយ និងកំពុងតែបំបៅដោះកូននាពេលបច្ចុប្បន្ន?

បាទ/ចាស អ្នកគួរតែបន្តផ្តល់វ៉ាក់សាំងដល់កូន ប្រសិនបើអ្នកបានចាក់វ៉ាក់សាំងរួចហើយនៅអំឡុងពេលមានផ្ទៃពោះ និង/ឬ ប្រសិនបើអ្នកកំពុងតែបំបៅដោះកូននាពេលបច្ចុប្បន្ន។ ពិតមែនតែអង់ទីករអាចចម្លងបន្តទៅកូននៅអំឡុងពេលមានផ្ទៃពោះនិងបំបៅដោះកូន ប៉ុន្តែការការពារអាចនឹងតិចតួចទៅពីពេលមួយទៅពេលមួយ។

## តើវ៉ាក់សាំងជំងឺ-19 មានសុវត្ថិភាពសម្រាប់កុមារតូចៗដែរឬទេ? ចុះចំណែកផលប៉ះពាល់រយៈពេលវែងវិញ?

បាទ/ចាស។ សុវត្ថិភាពវ៉ាក់សាំងត្រូវបានគេសិក្សាលើកុមារ 10,000នាក់ ដែលមានអាយុពី 6ខែដល់ 5ឆ្នាំ។ កុមារមួយចំនួនមានផលរំខានតិចតួច ដូចជាការអស់កម្លាំង ឬគ្រុនក្តៅជាដើម ប៉ុន្តែផលរំខាននេះមិនបានកើតមានរយៈវែងនោះទេ ហើយពួកគេទាំងអស់នោះបានជាសះស្បើយយ៉ាងឆាប់រហ័ស។វ៉ាក់សាំងកូវីដ-19 សម្រាប់កុមារ គឺជាប្រភេទវ៉ាក់សាំងដែលមានឈ្មោះថាវ៉ាក់សាំង mRNA ដែលគេបានសិក្សានៅក្នុងការពិសោធន៍សាកល្បងទៅលើសត្វនិងមនុស្សអស់រយៈពេលជាច្រើនឆ្នាំ ដោយពុំមានផលប៉ះពាល់អ្វីឡើយ។ដោយសារតែជំងឺកូវីដ-19 អាចធ្វើឲ្យកុមារធ្លាក់ខ្លួនឈឺ ការចាក់វ៉ាក់សាំងគឺជាជម្រើសដ៏ល្អបំផុតសម្រាប់សុខភាពនិងសុវត្ថិភាពរយៈពេលវែង។

## តើវ៉ាក់សាំងជំងឺកូវីដ-19 មានប្រសិទ្ធភាពដែរឬទេ?

បាទ/ចាស។ ការសាកល្បងព្យាបាលបានបង្ហាញថា វ៉ាក់សាំងសម្រាប់កុមារតូចៗគឺមានប្រសិទ្ធភាពក្នុងការកាត់បន្ថយអត្រានៃការឆ្លង និងក្នុងការបង្កើតកម្រិតភាពស៊ាំក្នុងកម្រិតប្រហាក់ប្រហែលលើខ្លួនកុមារ ដូចគ្នាទៅនឹងលើខ្លួនជំទង់និងមនុស្សពេញវ័យដែរ។

## តើកូនរបស់ខ្ញុំអាចទទួលការចាក់វ៉ាក់សាំងបាននៅកន្លែងណា?

ប្រសិនបើអាចធ្វើបាន សូមទាក់ទងទៅកាន់អ្នកផ្តល់សេវាថែទាំសុខភាពរបស់កូនអ្នកដើម្បីកំណត់ពេលណាត់ជួបពិគ្រោះ។ប្រសិនបើកូនរបស់អ្នកមិនមានអ្នកផ្តល់សេវាថែទាំសុខភាពនោះទេ សូមប្រើគេហទំព័រ VaxFinder.mass.gov ដើម្បីស្វែងរកការណាត់ជួបពិគ្រោះនៅតាមឱសថស្ថាន មណ្ឌលសុខភាព ឬទីតាំងផ្សេងទៀតដែលផ្តល់វ៉ាក់សាំងដល់កុមារតូចៗ។ការចាក់វ៉ាក់សាំងតាមផ្ទះ គឺមានផ្តល់ជូនសម្រាប់អ្នកដែលមានការលំបាកក្នុងការប្រើប្រាស់ទីតាំងចាក់វ៉ាក់សាំងតាមសហគមន៍។

**ស្វែងយល់បន្ថែមតាមរយៈ:**
mass.gov/CovidVaccineYoungKids

Massachusetts Department of Public Health